**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# លិខិតអនុញ្ញាត

ខ្ញុំបាទ / នាងខ្ញុំឈ្មោះ **ឈឹម ជា** អក្សរឡាតាំង **CHHIM CHEA** ភេទប្រុស ☑ ស្រី ☐
ថ្ងៃខែឆ្នាំកំណើត កើតថ្ងៃទី ០៥ ខែមិនា ឆ្នាំ១៩៧១ សញ្ជាតិ ខ្មែរ ជនជាតិ ខ្មែរ
ទីកន្លែងកំណើត នៅភូមិជីកដី ឃុំអណ្តូងត្របែក ស្រុករមាសហែក ខេត្តស្វាយរៀង ។
ជាប្រធានអង្គការទ្រទ្រង់ព្រះពុទ្ធសាសនាដើម្បីកម្ពុជាគ្រប់គ្រងនៅក្នុងប្រាសាទអង្គរថ្មីបូរីខ្មែរ ភូមិជីកដី ឃុំអណ្តូងត្របែក ស្រុករមាសហែក ខេត្តស្វាយរៀង ។

ខ្ញុំបាទឈ្មោះ **ភិន ស៊ីតារា** អក្សរឡាតាំង **PHIN SIDARA** ភេទប្រុស ☑ ស្រី ☐
ថ្ងៃខែឆ្នាំកំណើត កើតថ្ងៃទី ០៤ ខែវិច្ឆិកា ឆ្នាំ១៩៨១ សញ្ជាតិ ខ្មែរ ជនជាតិ ខ្មែរ
ទីកន្លែងកំណើត នៅភូមិគគីធំ ឃុំគគីធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល ។
មុខងារ ជាអគ្គលេខាធិការអង្គការទ្រទ្រង់ព្រះពុទ្ធសាសនាដើម្បីកម្ពុជា ។

សូមបញ្ជាក់ថា ខ្ញុំបាទ / នាងខ្ញុំ បានឯកភាពគ្នាក្នុងគណៈកម្មាធិការនាយកទាំងអស់ សូមប្តូរទីស្នាក់ការកណ្តាល ផ្ទះលេខ៩៩ ផ្លូវលេខ២០៧ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញមកបើកនៅក្នុងប្រាសាទអង្គរថ្មីបូរីខ្មែរដែលមានផ្ទៃក្រឡាដីទំហំ **1000m x 1000m** ដែលមានអាសយដ្ឋានដូចខាងលើធ្វើជាទីស្នាក់ការកណ្តាលសមាគម ☐ អង្គការ ☑ អង្គការទ្រទ្រង់ព្រះពុទ្ធសាសនាដើម្បីកម្ពុជា ចាប់ពីថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៥រហូតដល់ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០..... ដោយសន្យាថាមិនទទួលយកនូវប្រាក់កម្រៃឈ្នួលឡើយ ។ ប៉ុន្តែរាល់សោហ៊ុយចំណាយផ្សេងៗដូចជាថ្លៃទូទាត់ការប្រើប្រាស់ចរន្តអគ្គិសនី ទឹកស្អាត និងសេវាអនាម័យនោះសាមី សមាគម / អង្គការជាអ្នកធានារ៉ាប់រងទទួលបន្ទុកទាំងស្រុង ។

ធ្វើនៅ ជីកដី ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ២០១៥

**តំណាងសមាគម / អង្គការ** | **សាក្សី** | **ស្នាមមេដៃម្ចាស់អង្គការ**

ភិន ស៊ីតារា | | ឈឹម ជា

លេខ : ២៥៥៨

**បានឃើញ និងសូមបញ្ជាក់ថា:**
ស្នាមមេដៃនេះពិតជា របស់ឈ្មោះ ឈឹម ជា និងឈ្មោះ ភិន ស៊ីតារា ពិតប្រាកដមែន ។
អណ្តូងត្របែក ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ២០១៥
**មេឃុំ / ចៅសង្កាត់** អណ្តូងត្របែក

គង់_ទិត

ផែនទីបង្ហាញទីតាំងស្នាក់របស់

អង្គការគ្រូទ្រង់ព្រះពុទ្ធសាសនា ដើម្បីកម្ពុជា ស្ថិតនៅភូមិទឹកជី ឃុំអណ្តូងត្របែក

ស្រុករមាសហែក ខេត្តស្វាយរៀង




លេខ........ឃ.ជ......

..........................................

ថ្ងៃទី........ខែ.........២០១៤

មេឃុំ-ចៅសង្កាត់

គង់ _ ទិត

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខៈ ១២៣៥ សជណ

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៥

**ជម្រាបមក**
**លោក ឈឹម ជា ប្រធានអង្គសន្និបាត**
**នៃអង្គការទ្រទ្រង់ព្រះពុទ្ធសាសនាដើម្បីកម្ពុជា**

**កម្មវត្ថុ** : អំពីការសុំទទួលស្គាល់ប្រធាន និងសមាសភាពថ្មី នៃរចនាសម្ព័ន្ធ ព្រមទាំងប្តូរអាសយដ្ឋាន នៃទីស្នាក់ការកណ្តាលអង្គការទ្រទ្រង់ព្រះពុទ្ធសាសនាដើម្បីកម្ពុជា។

**យោង** :- លិខិតលេខ ១៥០៥ សជណ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០ របស់ក្រសួងមហាផ្ទៃ
- លិខិតលេខ ១៣/២០១៥ អ.ទ.ព.ក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៥ របស់អង្គការទ្រទ្រង់ព្រះពុទ្ធសាសនាដើម្បីកម្ពុជា។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោកប្រធានថា ក្រសួងមហាផ្ទៃបានយល់ព្រមទទួលស្គាល់លោក ឈឹម ជា ជាប្រធានអង្គការ និងសមាសភាពថ្មី នៃរចនាសម្ព័ន្ធ ព្រមទាំងប្តូរអាសយដ្ឋាន នៃទីស្នាក់ការកណ្តាលអង្គការទ្រទ្រង់ព្រះពុទ្ធសាសនាដើម្បីកម្ពុជា ពីផ្ទះលេខ៥៩ ផ្លូវលេខ០៧ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ មកតាំងនៅភូមិដីកដី ឃុំអណ្តូងត្របែក ស្រុករមាសហែក ខេត្តស្វាយរៀង តាមសំណើ។

ទន្ទឹមនេះ អង្គការទ្រទ្រង់ព្រះពុទ្ធសាសនាដើម្បីកម្ពុជា ត្រូវអនុវត្តសកម្មភាពការងារឲ្យស្របតាមលក្ខន្តិកៈដូចបានតម្កល់ទុកនៅក្រសួងមហាផ្ទៃ។

អាស្រ័យហេតុនេះ សូមលោកប្រធានជ្រាបជាព័ត៌មាន និងចាត់ចែងអនុវត្តតាមការគួរ។

ជ.រដ្ឋមន្ត្រី
រដ្ឋលេខាធិការ

ប៊ុល_លឹម

**ចម្លងជូន ៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
"ដើម្បីជូនជ្រាប"
- សាលារាជធានីភ្នំពេញ
- សាលាខេត្តស្វាយរៀង
"ដើម្បីមុខការ"
- ឯកសារ - កាលប្បវត្តិ

ទីស្តីការក្រសួងមហាផ្ទៃ លេខ ២៧៥ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣៧២៦០៥២-២៣៧២៦០៥៣
ទូរសារ (៨៥៥) ២៣៧២៦០៥២-២៣៧២៦០៥៣ e-mail: moi@interior.gov.kh web: www.interior.gov.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខ ១៤០៥ សជណ

រាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១០

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**ជម្រាបមក**
**លោក ឈឹម មនោ ប្រធានអង្គការទ្រទ្រង់ព្រះពុទ្ធសាសនាដើម្បីកម្ពុជា**

**កម្មវត្ថុ** : អំពីការសុំចុះបញ្ជីរបស់ *អង្គការទ្រទ្រង់ព្រះពុទ្ធសាសនាដើម្បីកម្ពុជា* នៅក្រសួង-មហាផ្ទៃ។

**យោង** : លិខិតលេខ *០០១.អ.ទ.ព.ក* ចុះថ្ងៃទី*១៩* ខែ*កញ្ញា* ឆ្នាំ*២០១០* ស្តីពីការសុំចុះបញ្ជីរបស់ *អង្គការទ្រទ្រង់ព្រះពុទ្ធសាសនាដើម្បីកម្ពុជា* ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោកប្រធានថា ក្រសួងមហាផ្ទៃយល់ព្រមចុះបញ្ជី *អង្គការទ្រទ្រង់ព្រះពុទ្ធសាសនាដើម្បីកម្ពុជា* ដែលមានអាសយដ្ឋាននៃទីស្នាក់ការកណ្តាលនៅផ្ទះលេខ*៩៩* ផ្លូវលេខ*០៧* សង្កាត់*ភ្នំពេញថ្មី* ខណ្ឌ*សែនសុខ* *រាជធានីភ្នំពេញ* នោះហើយ។ *អង្គការទ្រទ្រង់ព្រះពុទ្ធសាសនាដើម្បីកម្ពុជា* ត្រូវអនុវត្តតាមលក្ខន្តិកៈដូចបានតម្កល់ទុកនៅក្រសួងមហាផ្ទៃ និងធ្វើសកម្មភាពការងារក្នុងក្របខ័ណ្ឌជាអង្គការអព្យាក្រឹត មិនប្រកាន់ពូជសាសន៍ មិនប្រកាន់សាសនា មិនប្រកាន់និន្នាការនយោបាយ មិនធ្វើសកម្មភាពបម្រើឱ្យគណបក្សនយោបាយ និងមិនធ្វើជាឧបករណ៍គណបក្សនយោបាយ ។

ក្រោយពីច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលចូលជាធរមាន អង្គការទ្រទ្រង់ព្រះពុទ្ធសាសនាដើម្បីកម្ពុជា ត្រូវដាក់ពាក្យសុំចុះបញ្ជីសាជាថ្មីឱ្យបានត្រឹមត្រូវតាមច្បាប់ ។

អាស្រ័យហេតុនេះ សូមលោកប្រធានជ្រាបជាព័ត៌មាន ។
សូមលោកប្រធាន ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

ជ.រដ្ឋមន្ត្រី
រដ្ឋលេខាធិការ

នុត . សាអាន

***ចម្លងជូន :***
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- សាលារាជធានីភ្នំពេញ
  "ដើម្បីមុខការ"
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ**

លេខ:......៧៧០......សសរ

រាជធានីភ្នំពេញ, ថ្ងៃទី...២០...ខែ...ធ្នូ......ឆ្នាំ ២០១០.

# សេចក្ដីសម្រេច

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្ដីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
- លិខិតស្នើសុំលេខ ០០១ អគទពក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ របស់អង្គការគណៈកម្មាធិការទ្រទ្រង់ព្រះពុទ្ធសាសនាដើម្បីកម្ពុជា
- លិខិតលេខ ១៩០៥ សជណ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០ របស់ក្រសួងមហាផ្ទៃ
- លិខិតស្នើសុំលេខ ០០២ អទពក ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១០ របស់អង្គការទ្រទ្រង់ព្រះពុទ្ធសាសនាដើម្បីកម្ពុជា
- ចំណារឯកឧត្ដមរដ្ឋមន្ត្រី ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១០។

## សម្រេច

**ប្រការ ១ :** ប្ដូរឈ្មោះ អង្គការគណៈកម្មាធិការទ្រទ្រង់ព្រះពុទ្ធសាសនាដើម្បីកម្ពុជា មកជា អង្គការទ្រទ្រង់ព្រះពុទ្ធសាសនាដើម្បីកម្ពុជា។

**ប្រការ ២ :** អង្គការនេះ កសាងប្រាសាទចំនួន ១២ តាមលំនាំរចនាបទប្រាសាទអង្គតូច ស្ថិតនៅភូមិជីកជី ឃុំអង្គងត្របែក ស្រុករមាសហែក ខេត្តស្វាយរៀង ដែលមានក្រឡាផ្ទៃដីទំហំ ១,០០០ ម x ១,០០០ម ដោយមាន **ឧកញ៉ា ឈឹម មនោ** ជាប្រធានអង្គការ។ ក្នុងការសាងសង់អង្គការត្រូវសហការជាមួយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដើម្បីពិនិត្យក្បូនខ្នាតអោយបានត្រឹមត្រូវ។

**ប្រការ ៣ :** សេចក្ដីសម្រេចលេខ ២៦ សសរ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៩ ទុកជានិរាករណ៍ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រដ្ឋមន្ត្រី
រដ្ឋលេខាធិការ

ជុច_គឿន

**ចម្លងជូន :**

- សាលាខេត្តស្វាយរៀង
- អគ្គនាយកដ្ឋានបេតិកភណ្ឌ
- មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈខេត្តស្វាយរៀង
  "ដើម្បីជ្រាបជាព័ត៌មាន"
- ឯកសារ-កាលប្បវត្តិ